ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..................សហវ.......

ថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឱ្យដំណើរការ
## "គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ដំណាក់កាលទី២"

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់សហគ្រាសធុនតូច និងមធ្យម មេត្តាជ្រាបថា ក្រោមគំនិតផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលកម្ពុជា និងតាមរយៈកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម ក្នុងការអនុវត្តនូវគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ដំណាក់កាលទី ២ បន្ទាប់ពីទទួលបាននូវភាពជោគជ័យនៃគម្រោងទី១ ដើម្បីចូលរួមស្តារសេដ្ឋកិច្ចឡើងវិញ និងជួយដល់ អេស អ៊ឹម អ៊ី ដែលកំពុងត្រូវការហិរញ្ញវត្ថុ សម្រាប់ទ្រទ្រង់អាជីវកម្មបន្ត។ ***គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ដំណាក់កាលទី ២ ត្រូវបានបង្កើតឡើង និងដាក់ឱ្យដំណើរការជាផ្លូវការចាប់ពីពេលនេះតទៅ។*** គម្រោងសហហិរញ្ញប្បទាននេះ មានគោលបំណងផ្តល់ឥណទានមានការប្រាក់ទាប ដើម្បីជំរុញការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអាទិភាព ដូចជា ឧស្សាហកម្ម សេវាកម្ម និងពាណិជ្ជកម្ម សម្រាប់ជំនួសឱ្យការនាំចូល បម្រើសេចក្តីត្រូវការក្នុងស្រុក ឬបម្រើជាធាតុចូលនៅក្នុងការផលិតរបស់ក្រុមហ៊ុនធំៗ ជាដើម។ មូលនិធិក្រោមគម្រោងសហហិរញ្ញប្បទាននេះ មានទំហំទឹកប្រាក់ ១០០ លានដុល្លារអាមេរិក ដែលជាការផ្តល់សហហិរញ្ញប្បទានបដិភាគស្មើគ្នា រវាងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (ធ.ស.ក) និងគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម។ គ្រឹះស្ថានហិរញ្ញវត្ថុចូលរួម នៃគម្រោងសហហិរញ្ញប្បទាននេះ មានចំនួន ២៦ ក្នុងនោះ ធនាគារពាណិជ្ជចំនួន ២១, ធនាគារឯកទេស ចំនួន ១, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ចំនួន ៣, និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១។

សហគ្រាសធុនតូច និងមធ្យម ដែលមានតម្រូវការឥណទាន អាចដាក់ពាក្យស្នើសុំឥណទានក្រោមគម្រោងសហហិរញ្ញប្បទាននេះ នៅតាមគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមណាមួយ ដោយគោរពតាមលក្ខខណ្ឌរបស់គម្រោងសហហិរញ្ញប្បទាននេះ និងលក្ខខណ្ឌផ្តល់ឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុចូលរួមនីមួយៗ។

សហគ្រាសធុនតូច និងមធ្យម ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអាចទទួលបានឥណទាន ក្រោមគម្រោងសហហិរញ្ញប្បទាននេះ ត្រូវតែជាអាជីវកម្មដែលត្រូវបានកំណត់និយមន័យដូចខាងក្រោម÷



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

| វិស័យ | ចំនួនបុគ្គលិក | | និង | ផលរបរប្រចាំឆ្នាំ (ដុល្លារអាមេរិក) | | ឬ | ទ្រព្យសកម្ម | |
|---|---|---|---|---|---|---|---|---|
| | តូច | មធ្យម | | តូច | មធ្យម | | តូច | មធ្យម |
| ឧស្សាហកម្ម | ៥-៤៩ | ៥០-១៩៩ | | ៦២ ៥០០ - ៤០០ ០០០ | ៤០០ ០០១ - ២ ០០០ ០០០ | | ៥០ ០០០ - ៥០០ ០០០ | ៥០០ ០០១ - ១ ០០០ ០០០ |
| សេវាកម្ម និង ពាណិជ្ជកម្ម | ៥-៤៩ | ៥០-៩៩ | | ៦២ ៥០០ - ២៥០ ០០០ | ២៥០ ០០១ - ១ ៥០០ ០០០ | | ៥០ ០០០ - ២៥០ ០០០ | ២៥០ ០០១ - ៥០០ ០០០ |
| * លក្ខខណ្ឌផលរបរ ឬទ្រព្យសកម្ម ត្រូវកំណត់យកលក្ខខណ្ឌមួយណាដែលមានកម្រិតខ្ពស់ជាងគេ។ | | | | | | | | |

លក្ខខណ្ឌនៃឥណទានក្រោមគម្រោងសហហិរញ្ញប្បទាននេះ ត្រូវផ្តល់ឱ្យសហគ្រាសធុនតូច និងមធ្យម មានទំហំអតិបរមា ៥០០,០០០ ដុល្លារអាមេរិក ដែលបានបែងចែកសម្រាប់ប្រើប្រាស់ក្នុងគោលបំណងពីរ÷

១. ឥណទានសម្រាប់ការចំណាយមូលធន (វិនិយោគ) ត្រូវបានកំណត់ត្រឹមទំហំអតិបរមា ៥០០,០០០ ដុល្លារអាមេរិក

២. ឥណទានសម្រាប់ប្រើជាទុនបង្វិល ត្រូវបានកំណត់ត្រឹមទំហំអតិបរមា ៣០០,០០០ ដុល្លារអាមេរិក។ រយៈពេលកម្ចីសម្រាប់ឥណទានទាំងពីរប្រភេទ រហូតដល់ ៧ ឆ្នាំ។

អត្រាការប្រាក់នៃឥណទានផ្តល់ឱ្យសហគ្រាសធុនតូច និងមធ្យម ក្រោមគម្រោងសហហិរញ្ញប្បទាននេះ ត្រូវបានកំណត់ជាពីរគឺ÷

១. អតិបរមា ៦.៥% ក្នុងមួយឆ្នាំ សម្រាប់វិស័យអាទិភាពដែលបានចុះបញ្ជី

២. អតិបរមា ៧.៥% ក្នុងមួយឆ្នាំ សម្រាប់វិស័យដែលមិនមែនអាទិភាព និង/ឬមិនបានចុះបញ្ជី។

ហេតុដូច្នេះ ម្ចាស់សហគ្រាសធុនតូច និងមធ្យម ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ស្របតាមលក្ខខណ្ឌតម្រូវដូចបានជម្រាបជូនខាងលើ អាចដាក់ពាក្យស្នើសុំឥណទានក្រោមគម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម ជំហានទី ២ ដោយធ្វើការទំនាក់ទំនងផ្ទាល់ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួមណាមួយ ដូចមានរាយឈ្មោះក្នុងបញ្ជីភ្ជាប់ជាមួយ។

សម្រាប់ការសាកសួរព័ត៌មានបន្ថែម ឬមានចម្ងល់ផ្សេងៗ សូមទំនាក់ទំនងមកកាន់ ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក (ធ.ស.ក) ដូចព័ត៌មានលម្អិតខាងក្រោម÷

- អាសយដ្ឋាន÷ អគារលេខ ៣០ ផ្លូវប៉ាស្ទ័រ កែងផ្លូវព្រៃនគរ សង្កាត់ផ្សារថ្មីទី១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
- ទូរស័ព្ទលេខ÷ ០៩៦ ៨១១ ១១១៨
- អ៊ីម៉ែល ÷ info@smebankcambodia.com.kh
- គេហទំព័រ ÷ www.smebankcambodia.com.kh

# គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូច និងមធ្យម (SME CO-FINANCING SCHEME 2)

## ឈ្មោះ អាសយដ្ឋាន លេខទំនាក់ទំនង និងមូលនិធិបម្រុងសម្រាប់សហហិរញ្ញប្បទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុចូលរួម

| No | PFI Name (Khmer) | PFI Type | Address (Khmer) | Contact Person | Contact Person (Tel. number) | Contact Person (Email) |
|---|---|---|---|---|---|---|
| 1 | ធនាគារ អេស៊ីលីដា ភីអិលស៊ី | Bank | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Nhem Chamroeun | 010 800 311 | nhem.chamroeun@acledabank.com.kh |
| 2 | ធនាគារវឌ្ឍនៈអាស៊ីចំកាត់ | Bank | អគារលេខ ១៤១ ១៤៦ ១៤៨ និង ១៤៨ អា បេ សេ ដេ មហាវិថីព្រះសីហនុ និង ផ្ទះលេខ ១៥ និង ១៥៣ អា បេ សេ ផ្លូវលេខ២៧៨ ភូមិ៤ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Bidhu Pandey | 098 630 631 | pandey@ababank.com |
| 3 | ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ | Bank | អគារលេខ ២៦៥-២៦៩ វិថីព្រះបាទអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | Mr. Ung Rady | 070 600 075 | rady.ung@cpbankcambodia.com.kh |
| 4 | ធនាគារ ព្រីនស៍ ម.ក | Bank | ផ្ទះលេខ ១៧៥អាបេសេដេ មហាវិថីម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ | Mrs. Te Muyny | 012 638 188 | t.muyny@princebank.com.kh |
| 5 | ធនាគារ ហុង លីអុង (ខេមបូឌា)ភីអិលស៊ី | Bank | អគារលេខ ២៨ វុក្ខវិថីសម្តេចប៉ាន (ផ្លូវលេខ ២១៤) កែងផ្លូវប៉ាស្ទ័រ (ផ្លូវលេខ ៥១) សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ | Mr. Kaeut Nil | 016 555 849 | kaeutnil@hlbkh.hongleong.com |
| 6 | ធនាគារជីបម៉ុង ខមមើសលប៊ែង ម.ក | Bank | អគារលេខ១៣៧B មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកង ៣ ខណ្ឌចំការមន រាជធានីភ្នំពេញ | Mrs. Lay Rachana | 066 900 944 / 012 822 310 | rachana.lay@chipmongbank.com |
| 7 | ធនាគារ កាណាឌីយ៉ា ក.អ | Bank | លេខ៣១៥ មហាវិថីព្រះមនីវង្ស កែងវិថីព្រះអង្គឌួង សង្កាត់វត្តភ្នំ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Ms. Thone Lyhour | 017 908 816 | lyhour.thone@canadiabank.com.kh |
| 8 | ធនាគារ សហពាណិជ្ជ ក.អ | Bank | ផ្ទះលេខ ៦១ ផ្លូវ ១៣០ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ ភ្នំពេញ | Khom Pisey | 016 898 552 | Pisey-21004@email.ucb.com.kh |
| 9 | ធនាគារ អេស ប៊ី អាយ លីហ្សូ | Bank | អគារលេខ ២១៩ ផ្លូវ ១២៨ កែង ១៦៩ សង្កាត់មិត្តភាព ខណ្ឌ ០៧ មករា រាជធានីភ្នំពេញ | Mr. Loy Sareth | 012 821 482 | sareth.loy@sbilhbank.com.kh |
| 10 | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ | MDI | អគារលេខ ២១២ ផ្លូវ ២៧១ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ | Mr. Chea Hang | 097 764 8888 | cheahang@prasac |
| 11 | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី | Bank | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី (ការិយាល័យកណ្តាល) អគារលេខ ៤៣ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | Mr. Seng Sovidia | 012 726 800 | sovidia.seng@maybank.com |
| 12 | ធនាគារ ហត្ថា ម.ក | Bank | ផ្ទះលេខ606 ផ្លូវលេខ271 ភូមិសន្សំកុសល៣ សង្កាត់បឹងទំពន់ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | Mr. Khiev Vanna | 098 333 064 | vanna.khiev@hatthabank.com |
| 13 | ធនាគារ ស្ថាបនា ភីអិលស៊ី | Bank | អគារ ស្ថាបនា លេខ៦៣ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Sam Vanden | 096 424 4442 | sam.vanden@sathapana.com.kh |

| No | PFI Name (Khmer) | PFI Type | Address (Khmer) | Contact Person | Contact Person (Tel. number) | Contact Person (Email) |
|---|---|---|---|---|---|---|
| 14 | ធនាគារ អេស៊ា-ប៉ាស៊ីហ្វិកឌីវេឡុបមេន ម.ក | Bank | ឡូតិ៍លេខ132 ផ្លូវលេខ294 កែងនឹងមហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Svay Pisal | 017 333 382 | svay.pisal@apdbank.com.kh |
| 15 | ធនាគារ ភ្នំពេញ ពាណិជ្ជ ម.ក | Bank | អគារលេខ ២១៧ មហាវិថីព្រះនរោត្តមសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា | Mr. Kao Hakeang | 017 599 797 | k.hakeang@ppcb.com.kh |
| 16 | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក | Bank | ជាន់ទី ១, M, ២ & ៩ ផ្លូវ ៩៣ កែងផ្លូវ ១១០ ភូមិ៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ | Mr. Sok Leng | 016 755 766 | leng.sok@rhbgroup.com |
| 17 | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា | Bank | ផ្ទះលេខ៣៣ C-D វិថីឆេកូស្លូវ៉ាគី សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Ork Vanda | 081 666 921 | vanda.ork@ftbbank.com |
| 18 | គ្រឹះស្ថានខេមាមីក្រូហិរញ្ញវត្ថុ លីមីតធីត | MFI | ផ្ទះលេខ១០១អា ផ្លូវ ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ | Mr. Sok Samnang | 010 438 023 | samnang.sok@camma.com.kh |
| 19 | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី | Bank | លេខ ២០ អា/បេ កាច់ជ្រុងមហាវិថីព្រះនរោត្តម និងផ្លូវលេខ ១១៨ សង្កាត់ផ្សារចាស់ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | Mr. Hong Cheap | 012 333 799 | cheap.hong@cimb.com.kh |
| 20 | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត | MDI | ផ្ទះលេខ៨០ ផ្លូវលេខ៣១៥ ភូមិ៧ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Some Roatha | 077 469 490 | roatha.sroem@amret.com.kh |
| 21 | ធនាគារឯកទេស ដូនពេញ ម.ក | Specialized Bank | ផ្ទះលេខអេស២-២១ និងអេស២-២២ មហាវិថីហ្សាដឺហ្គោល (ផ្លូវលេខ ២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ | Mr. Chhan Ponloeu | 069 876 687 | ponloeu.chhan@dpbank.com.kh |
| 22 | ធនាគារ វឌ្ឍនៈ | Bank | ជាន់ទី២ វិមានវឌ្ឍនៈ កាពីតាល អគារលេខ៦៦ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Keo Chanvesna | 012 802 842 | kcveasna@vattanacbank.com |
| 23 | ធនាគារ ហ្វីលីព ភីអិលស៊ី | Bank | អាគារលេខ ២៧DEFG មហាវិថីព្រះមុន្នីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ លេខទូរស័ព្ទៈ (៨៥៥) ២៣ ៨៦២ ៧៧៧ លេខទូរសារៈ (៨៥៥) ២៣ ៨៦២ ៧២៧ | Mrs. Duong Kimlang | 016 222 129 | kimlang.duong@phillipbank.com.kh |
| 24 | សាខាធនាគារ អ៊ិនដាសស្ទ្រៀល បែ៊ង អហ្វ ខូរៀ "ភ្នំពេញ" | Bank | ទីក្រុងអូឡាំព្យា អគារលេខ S២-២៣ មហាវិថីព្រះមុនីរ៉េត (ផ្លូវលេខ ២១៧) សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Neang Sambo | 012 292 941 | neangsombo@ibk.co.kr |
| 25 | ធនាគារ ឌីជីប៊ី ម.ក | Bank | ផ្ទះលេខ ៦៨៩B មហាវិថីកម្ពុជាក្រោម សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Mey Vannak | 012 605 966 | meyvannak@dgbcambodia.com |
| 26 | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី | MDI | អគារលេខ២៨៥ មហាវិថីយោធពលខេមរភូមិន្ទ (ផ្លូវលេខ ២៧១) សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា | Mr. Tum Chandet | 093 796 888 | chandet.tum@amkcambodia.com |